កំណត់ត្រាគោលនយោបាយលេខ ៤

# ការណែនាំវិធីសាស្ត្រដើម្បីគាំទ្រ អង្គការអន្តរវិជ្ជាជីវៈ

ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ២០១៧

អ្នកនិពន្ធ៖ : Jean-Marie Brun, Celia Coronel, Laurent Liagre, IRAM [1]

iram

## មាតិកា

១. មូលដ្ឋានគ្រឹះ៖ គោលគំនិតនៃគណៈកម្មការអន្តរវិជ្ជាជីវៈ៖ តើអន្តរវិជ្ជាជីវៈជាអ្វី និងមានលក្ខណៈដូចម្តេច.......២
២.ការរំលឹកឡើងវិញនូវការចូលរួមរបស់គម្រោង SCCRP ក្នុងការបង្កើតអង្គការអន្តរវិជ្ជាជីវៈសម្រាប់វិស័យស្រូវអង្ករនៅកម្ពុជា.......................................................................................................៥
៣. ការណែនាំវិធីសាស្ត្រផ្សេងៗសម្រាប់ការបង្កើតអង្គការអន្តរវិជ្ជាជីវៈ...............................................១០

## អក្សរកាត់

| | | | |
|---|---|---|---|
| AFD | *ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង* | FO | អង្គការកសិករ |
| ARPEC | សម្ព័ន្ធអ្នកផលិត និងនាំចេញស្រូវអង្កររបស់កម្ពុជា | FWN | បណ្តាញកសិករ និងទឹក |
| CFAP | សហព័ន្ធសមាគមកសិករកម្ពុជានៃអ្នកផលិតកសិកម្ម | IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| CREA | សមាគមអ្នកនាំចេញស្រូវអង្ករកម្ពុជា | IRAM | វិទ្យាស្ថានស្រាវជ្រាវ និងអនុវត្តវិធីសាស្ត្រអភិវឌ្ឍន៍ |
| CRF | សហព័ន្ធស្រូវអង្ករកម្ពុជា | MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ExCo | គណៈកម្មធិការជំនួយ | MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| FAEC | សហព័ន្ធសមាគមជំរុញសហគ្រាសកសិកម្មជាលក្ខណៈគ្រួសារនៅកម្ពុជា | MoC | ក្រសួងពាណិជ្ជកម្ម |
| FCFD | សហព័ន្ធអង្គការកសិករកម្ពុជាដើម្បីអភិវឌ្ឍន៍ | SNEC | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ច |
| FCRE | សហព័ន្ធនាំចេញស្រូវអង្ករកម្ពុជា | SCCRP | គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា |
| FNN | បណ្តាញកសិករ និងធម្មជាតិ | SIAL | Salon International de l'Agroalimentaire (ទីក្រុងប៉ារីស) |

[1] www.iram-fr.org

ការបដិសេធ: ឯកសារនេះបង្ហាញតែពីទស្សនៈរបស់អ្នកនិពន្ធដែលមិនមែនជាទស្សនៈរបស់ AFD ឬ SNEC ទេ

នៅពេលមានការរៀបចំគម្រោងនេះឡើង គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជាទទួលបានអាណត្តិ ដើម្បីគាំទ្រអង្គការដែលស្ថិតក្នុងវិស័យស្រូវអង្ករកម្ពុជា និងដើម្បីកំណត់មូលដ្ឋានគ្រឹះក្នុងការបង្កើតអង្គការអន្តរវិជ្ជាជីវៈ។ ប៉ុន្តែ គោលគំនិតថាអ្វីទៅជាអង្គការអន្តរវិជ្ជាជីវៈនោះ គឺនៅមិនទាន់មានការកំណត់ច្បាស់លាស់នៅឡើយ។ ចំពោះដៃគូសន្ទនាមកពីទៅភ្នាក់ងារ AFD មានការយល់ឃើញថាពាក្យ "*interprofession*" (ជាភាសាបារាំង ដែលយើងបានបកប្រែនៅទីនេះថា អង្គការអន្តរវិជ្ជាជីវៈ) គឺសំដៅលើគោលគំនិតចម្បងនៅបារាំង ឬនៅសហគមន៍អឺរ៉ុបតាមក្របខណ្ឌច្បាប់ជាក់លាក់ ហើយក៏ប្រើប្រាស់នៅប្រទេសទីបីផងដែរ។ គោលគំនិតនេះគឺមានបង្ហាញនៅជំហានដំបូងនៃគម្រោង ហើយយើងរំលឹកឡើងវិញក្នុងផ្នែកទី ១ នៃកំណត់ត្រារបស់យើង (ខាងក្រោម) ស្តីពីមូលដ្ឋានគ្រឹះរបស់អង្គការអន្តរវិជ្ជាជីវៈ ដោយយោងតាមបទពិសោធន៍របស់ប្រទេសផ្សេងៗទៀត។ ផ្នែកទី ២ គឺរំលឹកឡើងវិញដោយសង្ខេបអំពីបទពិសោធន៍របស់គម្រោង SCCRP ដែលទាក់ទងនឹងអង្គការក្នុងវិស័យស្រូវអង្ករកម្ពុជា និងយកចិត្តទុកដាក់លើដែនកំណត់ដែលអាចធ្វើបានក្នុងស្ថានភាពបច្ចុប្បន្ន។ ផ្នែកទី ៣ ជាផ្នែកចុងក្រោយដែលផ្តោតសំខាន់លើការណែនាំយុទ្ធសាស្ត្រមួយចំនួនដែលអាចយកប្រើប្រាស់បានក្នុងករណីដែលអាជ្ញាធរសាធារណៈកម្ពុជាមានបំណងគាំទ្រដល់ការបង្កើតអង្គការវិជ្ជាជីវៈបន្ថែមក្នុងវិស័យស្រូវអង្ករកម្ពុជា ឬសម្រាប់សង្វាក់តម្លៃផ្សេងទៀត។

# ១. មូលដ្ឋានគ្រឹះ៖ គោលគំនិតនៃគណៈកម្មការអន្តរវិជ្ជាជីវៈ៖ តើអន្តរវិជ្ជាជីវៈជាអ្វី និងមានលក្ខណៈដូចម្តេច...

សមាគមនានាក្នុងខ្សែសង្វាក់តម្លៃកសិកម្មនឹងឃើញកើតមាននៅពាសពេញពិភពលោក។ កសិករ ពាណិជ្ជករ អ្នកជំនាញ អ្នកនាំចេញ និងអ្នកនាំចូល គឺតំណាងដោយសមាគមវិជ្ជាជីវៈ ឬអង្គភាពស្រដៀងនេះ។ អ្នកទាំងអស់នោះ ដើរតួយ៉ាងសំខាន់ក្នុងការជំរុញចំណាប់អារម្មណ៍របស់សមាជិករបស់ពួកគេ និងផ្តល់សេវាកម្មដែលមានប្រយោជន៍។ ម៉្យាងទៀត សហគម"អន្តរវិជ្ជាជីវៈ" តំណាងឱ្យខ្សែសង្វាក់តម្លៃទាំងមូល។ សមាគមអន្តរវិជ្ជាជីវៈ ឬសមាគមផលិតផលមានច្រើនទម្រង់ ហើយអនុវត្តទម្រង់ខុសៗគ្នាទៅតាមការកំណត់ទីតាំងភូមិសាស្ត្រ និងសេដ្ឋកិច្ចសង្គម។ ទោះបីយ៉ាងណា ពួកគេនៅតែមានគោលបំណង និងលក្ខណៈពិសេសមួយចំនួនជារួម។

## *១.១.តើអ្វីជាគោលបំណងរបស់សមាគមអន្តរវិជ្ជាជីវៈក្នុងវិស័យកសិកម្ម និងស្បៀងអាហារ?*

ដោយមានការទទួលស្គាល់ពីរដ្ឋ ជាទូទៅ សមាគមអន្តរវិជ្ជាជីវៈគឺជាអង្គភាពឯកជនដែលចូលរួមពីសមាជិកគ្រប់ជាន់ថ្នាក់ទាំងអស់នៃខ្សែសង្វាក់តម្លៃដូចគ្នា ដោយមានគោលបំណងបរិយាយលម្អិតពីគោលនយោបាយសម្របសម្រួលកែលម្អការអនុវត្តខ្សែសង្វាក់តម្លៃនេះ និងការពារអត្ថប្រយោជន៍សមាជិករបស់ខ្លួនទាំងស្រុង។

ក្នុងការអនុវត្តជាក់ស្តែង សមាគមន៍មួយចំនួនធ្វើការសម្របសម្រួលរហូតដល់មានការចុះកិច្ចព្រមព្រៀង ឬធ្វើឯកសារកំណត់តំណែងរួមមួយ ដើម្បីរៀបចំកិច្ចសន្ទនាជាមួយស្ថាប័នសាធារណៈ និងជាមួយដៃគូដែលទទួលអត្ថប្រយោជន៍ពីវិស័យនេះទាំងមូល។ យោងតាមភាពខុសគ្នានៃសមាគមវិជ្ជាជីវៈ ឬសមាគមពាណិជ្ជកម្ម គឺសមាគមទាំងនេះបង្កប់ទស្សនៈវិស័យ ខ្សែសង្វាក់តម្លៃ និងបញ្ជាក់ពីចំណាប់អារម្មណ៍ទូទៅដែលមានស្រាប់ក្នុងចំណោមភាគីពាក់ព័ន្ធខុសៗគ្នា។ នៅក្នុងអាណត្តិផ្ទាល់ខ្លួន សមាគមអន្តរវិជ្ជាជីវៈគឺមិនជំនួសឱ្យសមាគម

ពាណិជ្ជកម្មទេ ប៉ុន្តែពួកគេអាចទទួលបានអត្ថប្រយោជន៍រយៈពេលខ្លី និងប្រកបដោយកិត្តិយស ព្រោះយើងមិនអាចបង្កើតវិស័យមួយបានល្អឡើយ ប្រសិនបើភាគីពាក់ព័ន្ធនានាស្ថិតក្នុងស្ថានភាពអសមភាពខ្លាំងពេក។ សមាគមអន្តរវិជ្ជាជីវៈក៏ឈានដល់ការព្រមព្រៀងលើវិធានប្រតិបត្តិការទូទៅផងដែរ ដែលជួយពង្រឹងការអនុវត្តវិស័យនេះ។ មានការបញ្ជាក់ជាឧទាហរណ៍ថា ពួកគេអាចនឹងព្រួយបារម្ភលើការរៀបចំកិច្ចសន្យាលស្តង់ដារវាងអ្នកផលិត និងរោងចក្រ ចំពោះលក្ខណៈវត្ថុធាតុដើម និងបែបបទត្រួតពិនិត្យលើគុណភាព ការគណនាតម្លៃយោងតាមកម្រិតគុណភាព លេខកូដទូទៅលើផលិតផល ឬតម្លៃអប្បបរមាថ្នាក់ជាតិ។ ជាចុងក្រោយ ពួកគេអាចផ្តល់សេវាកម្មដូចជា ការផ្សព្វផ្សាយពីពាណិជ្ជសញ្ញា ឬសញ្ញាគុណភាព ព័ត៌មានទីផ្សារ ការផ្សព្វផ្សាយទីផ្សារក្នុងស្រុក និងទីផ្សារនាំចេញ។ល។ ពួកគេក៏គួរតែធ្វើការស្រាវជ្រាវបច្ចេកទេស ឬវិទ្យាសាស្ត្រផងដែរ ដើម្បីកែលម្អគុណភាព ការអនុវត្ត ឬការប្រកួតប្រជែងថ្នាក់ជាតិ។

## ១.២.ភាពជាតំណាង និងសមភាពជាចំណុចមូលដ្ឋានចម្បងៗនៃសមាគមអន្តរវិជ្ជាជីវៈ

ជាថ្មីម្តងទៀត សមាគមមួយដែលនឹងត្រូវចាត់ទុកថាជាសមាគមអន្តរវិជ្ជាជីវៈតែប៉ុណ្ណោះ លុះត្រាតែគ្រប់ភាគីពាក់ព័ន្ធទាំងអស់នៃខ្សែសង្វាក់នេះមានតំណាងត្រឹមត្រូវ (រួមមាន៖ កសិករ ពាណិជ្ជករ អ្នកកែច្នៃ អ្នកនាំចូល អ្នកនាំចេញជាដើម)។ នេះជាលក្ខខណ្ឌមួយក្នុងការគាំទ្រវិស័យនេះ និងការពារប្រយោជន៍របស់ខ្លួនដោយឈរលើមូលដ្ឋានដែលបានព្រមព្រៀង។

ជាគោលការណ៍ សមាជិកភាពត្រូវបានកម្រិតទៅតាមសមាគមវិជ្ជាជីវៈ ដែលតំណាងឱ្យដំណាក់កាលខុសៗគ្នានៅក្នុងខ្សែសង្វាក់នេះ។ ការកម្រិតនេះធានាបាននូវភាពជាតំណាងជាអប្បរមារបស់សមាគម។ វិធីសាស្ត្រ “អន្តរវិជ្ជាជីវៈ” ដ៏តឹងរឹងនេះ ធ្វើឡើងដើម្បីបែងចែកឱ្យដាច់ដោយឡែកពីសមាគមដែលអនុញ្ញាតឱ្យមានសមាជិកឯកត្តបុគ្គល។ ក្នុងករណីខ្លះ ទម្រង់ (កូនកាត់) ត្រូវបានបង្កើតឡើង ដែលមានសមាជិកភាពមកពីសមាគមផង និងឯកត្តបុគ្គលផង ឬក្រុមហ៊ុនផង។ ជាឧទាហរណ៍ នៅក្នុង “កិច្ចពិភាក្សាតុមូលស្តីពីខ្សែសង្វាក់តម្លៃ” នៅប្រទេសកាណាដា ទម្រង់ទាំងនេះបាននាំឱ្យភាគីពាក់ព័ន្ធរបស់ខ្សែសង្វាក់មកធ្វើការប្រជុំពិសេស ដែលអាចឱ្យពួកគេពង្រឹងទំនាក់ទំនងពាណិជ្ជកម្ម និងកំណត់បាននូវអត្ថប្រយោជន៍នានានៃការធ្វើការងាររួមគ្នា។ នេះជាជម្រើសវិធីសាស្ត្រមួយ ដែលធ្លាប់មានប្រសិទ្ធភាពក្នុងការរៀបចំកិច្ចសន្យាក្នុងវិស័យកសិកម្ម-ស្បៀងអាហារ ប៉ុន្តែវិធីសាស្ត្រនេះមិនប្រាកដថាអាចរៀបចំកិច្ចសន្ទនា និងកិច្ចចរចាផ្លូវការជាមួយរដ្ឋាភិបាលបានទេ។

កិច្ចសន្ទនាអន្តរវិជ្ជាជីវៈត្រូវបញ្ជាក់ជាចាំបាច់នូវការតំណាងដែលមានតុល្យភាព និងសំឡេងឆ្នោតស្មើគ្នារវាងប្រភេទនីមួយៗនៃភាគីពាក់ព័ន្ធ។ គំរូនៃការសម្រេចចិត្តអាចមានភាពខុសគ្នាពីសមាគមមួយទៅសមាគមមួយទៀត ប៉ុន្តែគោលការណ៍នៃភាពជាតំណាង និងសមភាពគឺនៅតែសំខាន់។

ក្នុងករណីសមាគម សហព័ន្ធ ឬសហជីពមួយចំនួននឹងមានក្នុងដំណាក់កាលនីមួយៗនៃខ្សែសង្វាក់នេះ នោះគោលការណ៍សមភាពអាចសម្រេចបានតាមរយៈក្រុមបោះឆ្នោត។ មានក្រុមអ្នកផលិតមួយក្រុម ពាណិជ្ជករមួយក្រុម និងអ្នកកែច្នៃមួយក្រុម។ ក្រុមនីមួយៗមានចំនួនសំឡេងឆ្នោតដូចៗគ្នា ដោយមិនគិតពីចំនួន

SCCRP ▪ កំណត់ត្រាគោលនយោបាយ

សមាជិកក្នុងក្រុម។ ការធ្វើបែបនេះ គឺដើម្បីជៀសវាងបញ្ហា "វិជ្ជាជីវៈ" មួយដែលមានសមាគមជាច្រើនលុប លើសមាគមមួយទៀតតែមួយសំឡេង ឬពីរសំឡេង។ នេះជាការទទួលខុសត្រូវរបស់សមាគមវិជ្ជាជីវៈនីមួយៗ ក្នុងការធ្វើកិច្ចព្រមព្រៀងជាមួយក្រុមរបស់ខ្លួនក្នុងតំណែងដែលទទួលបានសំឡេងឆ្នោតពីក្រុម មុនពេលមាន កិច្ចប្រជុំក្រុមប្រឹក្សាភិបាលម្តងៗ។

## *១.៣. តើសមាគមអន្តរវិជ្ជាជីវៈមានទំនាក់ទំនងអ្វីខ្លះជាមួយនឹងវិស័យសាធារណៈ?*

ស្ថាប័នអន្តរវិជ្ជាជីវៈជាទូទៅមានលក្ខណៈជាឯកជន ទោះបីជាមានករណីខ្លះមានការតំណាងពីរដ្ឋក៏ដោយ (ទោះបីជាធម្មតាត្រឹមជាអ្នកអង្កេតការណ៍ក៏ដោយ)។ តាមធម្មតា សមាគមអន្តរវិជ្ជាជីវៈត្រូវបានគ្រប់គ្រងដោយ ច្បាប់ជាក់លាក់ ដែលបានធានានូវភាពជាតំណាងរបស់ពួកគេ ហើយត្រូវតែធានាថាអ្នកតំណាងទាំងនោះមាន សិទ្ធិគ្រប់គ្រាន់នៅក្នុងការបញ្ចេញមតិក្នុងនាមជាសមាជិកខ្សែសង្វាក់ទាំងមូល (គោលការណ៍សមភាព)។

ដោយឈរលើតែមូលដ្ឋាននេះប៉ុណ្ណោះ នោះសមាគមអន្តរវិជ្ជាជីវៈ គឺជាចំណុចយោងមួយដើម្បីឱ្យរដ្ឋាភិបាល រៀបចំកិច្ចសន្ទនាតាមវិស័យដែលផ្តល់ឱ្យ។ តាមពិត តំណែងដែលទទួលបានដោយការបោះឆ្នោតតាមវិស័យ គឺបានរៀបចំឡើងដោយឈរលើមូលដ្ឋានប្រជាធិបតេយ្យ ដោយផ្តល់ឱ្យពួកគេនូវភាពខ្លាំង និងស្របច្បាប់។

នៅពេលអនុវត្ត សមាគមទាំងនេះអាចស្នើសុំគោលនយោបាយ និងវិធានបទបញ្ញត្តិទៅរដ្ឋាភិបាល ដែលនឹង អាចលើកកម្ពស់ការអភិវឌ្ឍវិស័យនេះទាំងមូលបាន។ វិធានការទាំងនេះរួមមានការទទួលស្គាល់ក្រមសីលធម៌ សាធារណៈ ស្តង់ដាគុណភាព ពន្ធ និងមូលនិធិអភិវឌ្ឍន៍ជាដើម។ ស្របពេលនោះដែរ អង្គការវិជ្ជាជីវៈមានតួ នាទីក្នុងការផ្សព្វផ្សាយបន្ត និងលើកទឹកចិត្តឱ្យមានការគោរពតាម "ការអនុវត្តល្អបំផុត" ក្នុងចំណោមសមាជិក របស់ពួកគេ។

**ប្រអប់លេខ ១៖ គម្រូអន្តរវិជ្ជាជីវៈនៅប្រទេសបារាំង**

នៅប្រទេសបារាំងមានសមាគមអន្តរវិជ្ជាជីវៈប្រហែល ៦០ សមាគម ដែលមានការគ្រប់គ្រងតាមស្ថានភាពជាក់លាក់ និងដាច់ដោយ ឡែកពីសមាគមដទៃទៀត។ រដ្ឋទទួលស្គាល់សមាគមមួយជា "*អន្តរវិជ្ជាជីវៈ*" ដោយប្រគល់អំណាចនិយតកម្មខ្លះ។ កិច្ចព្រមព្រៀង ដែលធ្វើឡើងដោយអង្គការវិជ្ជាជីវៈបានក្លាយជាច្បាប់ និងអនុវត្តចំពោះប្រតិបត្តិករទាំងអស់ក្នុងវិស័យនេះ។ យ៉ាងណាក៏ដោយ ដើម្បី មានអំណាចនិយមតកម្មនេះ *អន្តរវិជ្ជាជីវៈ* ត្រូវតែមានការបង្កើតឡើងតាមគោលការណ៍ណែនាំ ៣ យ៉ាងដែលគ្រប់គ្រងដោយរដ្ឋ៖

១. អង្គការជាសមាជិកនីមួយៗ ត្រូវតែតំណាងពេញលេញក្នុងដំណាក់កាលខ្សែសង្វាក់ដែលពួកគេតំណាង។ ប្រសិនបើគ្មានតំណាង ពេញលេញទេ នោះសមាគមនអង្គការអន្តរវិជ្ជាជីវៈនឹងបាត់បង់ភាពស្របច្បាប់របស់ខ្លួន។

២. ត្រូវតែមានសមភាពរវាងអង្គការ "វិជ្ជាជីវៈ" នានា ប្រសិនបើចាំបាច់ត្រូវប្រើប្រាស់តាមក្រុម។ សមាគមនទាំងអស់ត្រូវតែទទួលការ ប្រព្រឹត្តចំពោះដោយសមភាព និងមានចំនួនសំឡេងឆ្នោតដូចគ្នា។

៣. ត្រូវតែមានការមូលមតិគ្នាក្នុងកាសម្រេចចិត្ត។ ខណៈដែលមានការខ្វែងគំនិតគ្នារវាងសមាជិក តាមគោលការណ៍ដែលមានការ ទទួលស្គាល់គឺ សមាគមនអន្តរវិជ្ជាជីវៈអាចថ្លែង និងដើរតួជំនួសឱ្យសមាជិកទាំងអស់។ ប្រសិនបើមានករណីអ្វីមួយ ត្រូវតែមានការ សម្រេចចិត្តមូលមតិគ្នា ប៉ុន្តែសមាជិកនីមួយៗនៃក្រុមប្រឹក្សាភិបាលមានសិទ្ធិបដិសេធ។

ឧទាហរណ៍ សមាគមនអន្តរវិជ្ជាជីវៈផ្នែកបន្លែ និងផ្លែឈើស្រស់មានពីរ "ក្រុម" តំណាងឱ្យសមាគមអ្នកផលិតចំនួនបួន និងសមាគម អ្នកលក់ដុំ អ្នកនាំចេញ និងអ្នកលក់រាយចំនួនបួន។ អន្តរវិជ្ជាជីវៈផ្នែកសាច់ និងអាហារសត្វ ត្រូវបានចង់ក្រងជា ១៣ អង្គការវិជ្ជាជីវៈ ថ្នាក់ជាតិដែលតំណាងវិជ្ជាជីវៈដូចជា កសិករ ពាណិជ្ជករ អ្នកសម្លាប់សត្វ អ្នកធ្វើម្ហូប និងអ្នកចែកចាយ។

**ប្រអប់លេខ ២៖ គណៈកម្មការអន្តរវិជ្ជាជីវៈស្រូវអង្ករនៅប្រទេសហ្គាណា (GRIB)**

GRIB បានបង្កើតឡើងក្នុងឆ្នាំ ២០០៤ នៅប្រទេសហ្គាណា ដើម្បីរៀបចំកិច្ចសន្ទនាក្នុងវិស័យស្រូវអង្ករ និងរៀបជាទម្រង់កិច្ចសន្ទនារវាងប្រតិបត្តិករឯកជន និងរដ្ឋ។ ក្នុងវិស័យនេះ គឺមានការប្រឈមមុខទៅនឹងបញ្ហាសំខាន់ៗ ដូចជាការប្រកួតប្រជែងជាមួយស្រូវអង្ករនាំចូលទីផ្សារក្នុងស្រុកនៅតំបន់លិចទឹក និងតំបន់ជនបទ។ ក្នុងទស្សនៈនោះ ភាគីពាក់ព័ន្ធ អ្នកផលិត ពាណិជ្ជករ ម្ចាស់រោងម៉ាស៊ីនកិនស្រូវទាំងអស់បានព្រមព្រៀងធ្វើការប្រឹងប្រែងរួមគ្នា ដើម្បីពង្រឹងគុណភាពផលិតផលក្នុងស្រុកឱ្យឆ្លើយតបនឹងតម្រូវការអ្នកប្រើប្រាស់។ យ៉ាងណាក៏ដោយ គ្រប់ដំណាក់កាលនៃខ្សែសង្វាក់ស្រូវអង្ករទាំងអស់មិនទាន់មានការរៀបចំល្អក្នុងសមាគមអាជីវកម្មនៅឡើយ គឺវានៅដាច់ដោយឡែកពីសមាគមអ្នកផលិត ឬម្ចាស់រោងម៉ាស៊ីនកិនស្រូវមួយចំនួននៅតាមកម្រិតតំបន់មូលដ្ឋាន។ ប៉ុន្តែមានការខិតខំមួយចំនួនគឺបានធ្វើឱ្យភាគីពាក់ព័ន្ធតាមប្រភេទនីមួយៗ និងមានតំបន់ផលិតស្រូវអង្ករនីមួយៗរបស់ប្រទេសហ្គាណាមកចូលជាតំណាង និងចូលរួមក្នុងការសម្រេចចិត្ត។ មានការគ្រប់គ្រងសមាជិក GRIB គឺដើម្បីបង្កើតទស្សនៈវិស័យរួមផ្តោតលើបញ្ហា និងបញ្ហាប្រឈមលើវិស័យនេះ និងដើម្បីបង្កើតសេវាកម្មមានប្រយោជន៍មួយចំនួន (ព័ត៌មានទីផ្សារ) ទៅសមាជិកទាំងអស់។ ពួកគេបានរៀបចំធ្វើពិព័រណ៍ស្រូវអង្ករឡើង។ ពួកគេទាំងអស់គ្នាបានតស៊ូដើម្បីធ្វើឱ្យរដ្ឋាភិបាលបង្កើត "មូលនិធិអភិវឌ្ឍន៍ស្រូវអង្ករ" តាមរយៈពន្ធលើការនាំចូល។

# ២. ការរំលឹកឡើងវិញនូវការចូលរួមរបស់គម្រោង SCCRP ក្នុងការបង្កើតអង្គការអន្តរវិជ្ជាជីវៈសម្រាប់វិស័យអង្ករនៅកម្ពុជា

## *២.១. ដំណាក់កាលដំបូងរបស់គម្រោង SCCRP ៖ ដំណើរការនៃការកែទម្រង់ពាក់ព័ន្ធនឹងសហព័ន្ធ FCRE*

ដោយភ្ជាប់ជាឧបសម្ព័ន្ធកិច្ចព្រមព្រៀងហិរញ្ញប្បទាន ការបរិយាយអំពីវិសាលភាព និងគោលបំណងរបស់គម្រោង SCCRP បានផ្តល់អាណត្តិដល់គម្រោងនេះ ដើម្បីគាំទ្រអង្គការវិជ្ជាជីវៈរបស់អ្នកនាំចេញ និងកំណត់មូលដ្ឋានសម្រាប់ការបង្កើតស្ថាប័នអន្តរវិជ្ជាជីវៈ។ នៅដំណាក់កាលដំបូងនៃការអនុវត្តគម្រោង SCCRP គឺគណៈកម្មការដឹកនាំគម្រោង[2] បានយល់ព្រមលើគោលការណ៍នៃការគាំទ្រសហព័ន្ធអ្នកនាំចេញអង្ករកម្ពុជា (FCRE)។ ទោះបីជាវាត្រូវបានគេដាក់ឈ្មោះថាជាអង្គការនាំចេញក៏ដោយ ក៏សមាជិកភាពរបស់ FCRE មានទំហំធំជាងមុនព្រោះវាមិនត្រឹមតែរួមបញ្ចូលក្រុមហ៊ុននាំចេញអង្ករទេ ប៉ុន្តែរួមទាំងអាជីវកម្មកិនស្រូវ ក្រុមហ៊ុនលក់ឧបករណ៍នៃម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុនដឹកជញ្ជូន និងធនាគារផងដែរ។ លើសពីនេះទៅទៀត លក្ខន្តិកៈរបស់សហព័ន្ធបានបញ្ជាក់ថាសហព័ន្ធ FCRE នឹង "ប្រមូលផ្តុំអ្នកផលិតករ ឧស្សាហករ និងអង្គភាពពាក់ព័ន្ធផ្សេងៗទៀត ដើម្បីអភិវឌ្ឍ និងផ្សព្វផ្សាយការនាំចេញអង្ករកម្ពុជា" ។ គុណសម្បត្តិទាំងនេះអាចធ្វើឲ្យហៅសហព័ន្ធ FCRE លើសពីឈ្មោះអង្គការវិជ្ជាជីវៈ តែមិនមែនជាអង្គការអន្តរវិជ្ជាជីវៈទេ។



[2] ដែលរួមបញ្ចូល SNEC, MoC, MAFF ...

ដំណើរការផ្ដត់ផ្គង់ដល់សហព័ន្ធ FCRE គឺផ្អែកលើការគាំទ្របើកទ្រូតដែលបានអនុវត្តដោយលក្ខណៈស៊ីគ្នា និងប្រទាក់គ្នា[3] ៖

- ការគាំទ្រប្រតិបត្តិការសម្រាប់បង្កើតសេវាដល់សមាជិករបស់ខ្លួន (ការកំណត់ និងការអនុវត្តលើសេវាកម្មរហ័សដោយសហព័ន្ធដែលនឹងពង្រឹងសមត្ថភាព ទិស្សមានភាព និងភាពស្របច្បាប់របស់សហព័ន្ធចំពោះសមាជិករបស់ខ្លួន រួមទាំងការចូលរួមចំណែកក្នុងការជ្រើសរើសបុគ្គលិកដែលមានជំនាញ និងការផ្ដត់ផ្គង់ថវិកាដើម្បីគ្របដណ្ដប់លើការចំណាយចាំបាច់ "ដូចការផ្ដល់មូលនិធិលើគ្រាប់ពូជ") ជាដើម។
- ការគាំទ្រចំពោះការអនុវត្តយ៉ាងហ្មត់ចត់លើផែនការយុទ្ធសាស្ត្រចម្រុះ និងផែនការសកម្មភាពប្រចាំឆ្នាំដែលចេញជាសុពលភាពដោយសមាជិកទាំងអស់ (មហាសន្និបាត) រួមបញ្ចូលទាំងការព្រមព្រៀងលើថវិកា និងផែនការហិរញ្ញវត្ថុ ដើម្បីពង្រឹងភាពជាម្ចាស់របស់សមាជិក។
- ការគាំទ្រដល់ការពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធ និងតួនាទីរបស់សហព័ន្ធ ដើម្បីបញ្ជាក់ពីសមាជិកភាព (មានលក្ខណៈជាអ្នកឯកទេស ឬអន្តរវិជ្ជាជីវៈនៃសហព័ន្ធ) និងអភិបាលកិច្ចរបស់ FCRE ។

ដំណើរការនេះបានសង្កត់ធ្ងន់លើការពិភាក្សាជាមួយភាគីពាក់ព័ន្ធ (សមាជិកសហព័ន្ធ FCRE និងអ្នកដែលមិនមែនជាសមាជិក) លើមូលដ្ឋានឯកត្តបុគ្គល និងពហុភាគី ដើម្បីកែសម្រួលអង្គការដោយគិតគូរពីការរំពឹងទុករបស់សមាជិក។ ឆន្ទៈរបស់អ្នកដឹកនាំសហព័ន្ធ FCRE ក្នុងការទទួលយកដោយយុត្តិធម៌នូវវិន័យនៃប្រតិបត្តិការដែលបានស្នើឡើងដោយគម្រោង SCCRP និងជាពិសេសទស្សនវិស័យនៃកំណែទម្រង់ដ៏ទូលំទូលាយរបស់អង្គការនេះ គឺមានលក្ខណៈគួរឱ្យកត់សម្គាល់ ហើយសមនឹងទទួលបាននូវការគូសបញ្ជាក់។ អនុស្សារណៈនៃការយោគយល់គ្នាត្រូវបានចុះហត្ថលេខារវាងគម្រោង SCCRP និងសហព័ន្ធ FCRE នៅខែសីហាឆ្នាំ ២០១៣ ដោយកំណត់និយមន័យលើខ្លឹមសារ និងទម្រង់របស់គម្រោងគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ និងភ្ជាប់ជាមួយនឹងការតម្រង់ទិសដ៏ច្បាស់លាស់ដែលបានកំណត់ពីតួនាទី និងការប្ដេជ្ញាចិត្ត និងគោលដៅដែលមានដំណាក់កាលបីខែ (ដំណាក់កាលចំនួន ៦ វគ្គដែលមានរយៈពេលសរុប ១៨ ខែ) រួមទាំងគោលបំណងដើម្បីសម្រេចបាននៅដំណាក់កាលនីមួយៗដែលជាលក្ខខណ្ឌ ដើម្បីបើកជាផ្លូវដល់ការផ្ដត់ផ្គង់ដំណាក់កាលបន្ទាប់។ លើសពីនេះទៀត គម្រោងសម្របសម្រួលដ៏ល្អមួយត្រូវបានបង្កើតឡើងជាមួយដៃគូអភិវឌ្ឍន៍ដទៃទៀតដែលពាក់ព័ន្ធនឹងការផ្ដត់ផ្គង់ដល់សហព័ន្ធ ជាពិសេសសាជីវកម្ម IFC។

ប្រអប់លេខ ១ (ខាងក្រោម) សង្ខេបនូវអ្វីដែលបានសម្រេចក្នុងពេលប្រហែល ៦ ខែដែលជាផ្នែកមួយនៃការគាំទ្រដល់សហព័ន្ធ FCRE ។

[3] Cf. SCCRP "យុទ្ធសាស្ត្រអនុវត្តសម្រាប់សមាសភាគទី 1: ការរៀបចំផ្នែកស្រូវនិងការពង្រឹងសមត្ថភាពអ្នកដែលពាក់ព័ន្ធសេចក្ដីព្រាងចុងក្រោយចុះ " ថ្ងៃទី11 ខែមេសាឆ្នាំ 2013 និងបានដាក់ជូនគណៈកម្មាធិការដឹកនាំគម្រោងនៅថ្ងៃទី 19 ខែមេសាឆ្នាំ 2013។

## ប្រអប់លេខ ១៖ ដំណើរការកំណែទម្រង់ដែលចាប់ផ្តើមជាមួយសហព័ន្ធ FCRE និងទីតាំងដែលឈប់ដំណើរការ

នៅចុងឆ្នាំ ២០១៣ (ត្រឹមតែរយៈពេល ៥ ខែប៉ុណ្ណោះ បន្ទាប់ពីកិច្ចព្រមព្រៀងដៃគូត្រូវបានចុះហត្ថលេខារវាងគម្រោង SCCRP និងសហព័ន្ធ FCRE) សហព័ន្ធ FCRE ចាប់ផ្តើមបង្ហាញការកែលម្អប្រតិបត្តិការគួរឱ្យកត់សម្គាល់ជាមួយបុគ្គលិកថ្មី (នាយកប្រតិបត្តិ និងមន្ត្រីទំនាក់ទំនង) ការកែលម្អឧបករណ៍ប្រាស្រ័យទាក់ទង (វិបសាយ និងសារព័ត៌មាន) ការគ្រប់គ្រងដែលប្រសើរ និងមានតម្លាភាព (ប្រព័ន្ធគណនេយ្យ ការគ្រប់គ្រប់ធនធានមនុស្ស...) និងការអនុវត្តសេវាកម្ម និងព្រឹត្តិការណ៍នានា (ការចូលរួមយ៉ាងសកម្មក្នុងពិធីបុណ្យអង្ករកម្ពុជាលើកទី ១ និងការរៀបចំសន្និសីទស្តីពីបទពិសោធន៍លើកកម្ពស់កេរ្តិ៍ឈ្មោះរួមគ្នា...)។

ប្រព័ន្ធថ្លៃចូលជាសមាជិកត្រូវបានអនុម័ត ដោយផ្អែកលើថ្លៃចូលជាសមាជិកតាមលទ្ធភាពជារួម (ដើម្បីជៀសវាងការមានឧបសគ្គផ្នែកហិរញ្ញវត្ថុ និងធានាបាននូវការចូលរួមច្រើន) ប៉ុន្តែក៏មានជម្រើសពិសេសផងដែរ (ប្រាក់ មាស និងផ្លាទីន) ដើម្បីផ្តល់លទ្ធភាពឱ្យសហព័ន្ធក្នុងការបង្កើតធនធានបន្ថែម និងដំណើរការរបស់អង្គភាព។ ត្រឹមតែមួយខែប៉ុណ្ណោះ បន្ទាប់ពីការអនុម័តគោលនយោបាយថ្លៃចូលជាសមាជិកថ្មីនេះ សហព័ន្ធ FCRE ប្រមូលបានជាង ២២ ០០០ ដុល្លារអាមេរិកពីសមាជិក។

ដោយដកស្រង់ពីទិដ្ឋភាពរួម គេបានរៀបចំសេណារីយ៉ូ ៣ សម្រាប់ការកំណែទម្រង់ស្ថាប័ន (គិតពិចារណាលើធាតុចូលពីសមាជិក) និងបានបញ្ចូលទៅការបោះឆ្នោតនៅអំឡុងមហាសន្និបាតនៅថ្ងៃទី ២២ ខែមករា ឆ្នាំ ២០១៤។

ដោយឡែក អ្នកដែលមិនមែនជាសមាជិកត្រូវបានអញ្ជើញឱ្យចូលរួម និងអនុញ្ញាតឱ្យបោះឆ្នោតលើសេណារីយ៉ូនេះ។ គោលបំណងនេះ គឺដើម្បីបង្ហាញឆន្ទៈក្នុងការរួមបញ្ចូលអ្នកដែលមិនមែនជាសមាជិក និងគិតពិចារណាលើការរំពឹងទុករបស់ពួកគេ (និងលើកហេតុផលថាហេតុអ្វីបានជាពួកគេមិនចូលរួមសហព័ន្ធ)។ លើសពីនេះទៀត ដើម្បីដោះស្រាយបញ្ហាភាពមិនស្មើគ្នានៃការតំណាងរបស់ភាគីពាក់ព័ន្ធផ្សេងៗគ្នា ការបោះឆ្នោតលើសេណារីយ៉ូទាំងនេះ ត្រូវអនុវត្តដោយ "ក្រុម" មានន័យថា ការបោះឆ្នោតរបស់អ្នកផលិតម្ចាស់រោងម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុននាំចេញ និងអ្នកផ្តល់សេវា ត្រូវបានរាប់ដាច់ដោយឡែកពីគ្នា ហើយដើម្បីទទួលបានការអនុម័ត ជម្រើសដែលបានស្នើត្រូវតែទទួលបានសំឡេងឆ្នោតភាគច្រើនក្នុងចំណោមប្រភេទទាំងបួននេះ (បោះឆ្នោតយកសំឡេងភាគច្រើនក្នុងក្រុមនីមួយៗ ប៉ុន្តែតម្រូវឱ្យបោះឆ្នោតដោយអនាមិកពីក្រុមទាំងអស់ ដែលអនុវត្តតាមគោលការណ៍ដែលប្រើ ពេលគឺច្បាប់ក្នុងអង្គការអន្តរវិជ្ជាជីវៈនៅអឺរ៉ុប)។ វិធីសាស្ត្រដែលស្នើនេះបានដំណើរការ ហើយសេណារីយ៉ូសម្រាប់កំណែទម្រង់សហព័ន្ធ FCRE ត្រូវបានអនុម័ត ដោយមានភាពជាម្ចាស់និងការការពារដ៏រឹងមាំរបស់ភាគីពាក់ព័ន្ធនៃសង្វាក់តម្លៃ។ លើសពីនេះ គោលកាណ៍អភិបាលកិច្ចសំខាន់ៗមួយចំនួនក៏ត្រូវបានព្រមព្រៀងដោយការបោះឆ្នោតផងដែរ ដោយផ្តល់ជាគោលការណ៍ណែនាំសម្រាប់ការសរសេរលក្ខន្តិកៈសហព័ន្ធ FCRE ឡើងវិញ ដែលជាជំហានបន្ទាប់ក្រោយពីមហាសន្និបាតនៅខែមករា ឆ្នាំ ២០១៤ ។

ដំណើរការនេះបានដល់ទីបញ្ចប់នៅក្នុងរយៈមិនដល់មួយខែផង បន្ទាប់ពីបញ្ចប់មហាសន្និបាទដ៏ជោគជ័យ និងក្រោយពីបញ្ចប់កិច្ចពិភាក្សាឯកតោភាគីពីក្រសួងពាណិជ្ជកម្មដែលជំរុញសហព័ន្ធ FCRE សម្ព័ន្ធ ARPEC និងសមាគម CREA ដើម្បីបញ្ចូលជាស្ថាប័នតែមួយ។

## ២.២. ការបង្កើតសហព័ន្ធស្រូវអង្ករកម្ពុជា

ខណៈដែលដំណើរការនេះបានចូលរួមជាមួយកំណែទម្រង់របស់សហព័ន្ធ FCRE ហាក់ដូចជាស្ថិតក្នុងស្ថានភាពត្រឹមត្រូវ សហព័ន្ធស្រូវអង្ករកម្ពុជាត្រូវបានបង្កើតឡើងនៅដើមឆ្នាំ ២០១៤ ដោយអនុវត្តតាមការបង្គាប់របស់ក្រសួងពាណិជ្ជកម្ម ឱ្យរួមបញ្ចូលគ្នានូវអង្គភាពទាំងបីរបស់វិស័យស្រូវអង្ករ។ សេចក្តីសម្រេចលើការរួមបញ្ចូលគ្នានេះបានបញ្ចប់ដំណើរការចូលរួមកំណែទម្រង់របស់សហព័ន្ធ FCRE ខណៈដែលដំណើរការបង្កើតសហព័ន្ធស្រូវអង្ករកម្ពុជា (ជាស្ថាប័នថ្មីដែលកើតចេញពីការរួមបញ្ចូលគ្នានេះ) មិនបានដាក់បញ្ចូលភាគីពាក់ព័ន្ធវិស័យនេះយ៉ាងទូលំទូលាយទេ (សេចក្តីសម្រេចនៃការរួមបញ្ចូលគ្នាមិនត្រូវបានបញ្ជូនឱ្យធ្វើការអនុម័តពីមហាសន្និបាតរបស់អង្គភាពទាំងបីទេ) ហើយលក្ខន្តិកៈដំបូងរបស់សហព័ន្ធ CRF ក៏មិនត្រូវបានបញ្ជូនដើម្បីទទួលបានការអនុញ្ញាតពីមហាសន្និបាត[4]ផងដែរ។

នៅខែមករា ឆ្នាំ ២០១៤ ភាគីពាក់ព័ន្ធជាច្រើនក្នុងវិស័យស្រូវអង្ករ បានបង្ហាញការពេញចិត្តរបស់ខ្លួនពាក់ព័ន្ធនឹងដំណើរការកំណែទម្រង់សហព័ន្ធ FCRE ដោយចង់បញ្ចេញមតិ (ដូចបង្កើនភាពជាកម្មសិទ្ធិ) លើគោលបំណង និងរចនាសម្ព័ន្ធរបស់អង្គភាព ហើយការបង្កើតសហព័ន្ធ CRF បានក្លាយជាដំណើរការកាន់តែមានលក្ខណៈការិយាល័យធិបតេយ្យ និងផ្តល់ឱកាសឱ្យតែភាគីពាក់ព័ន្ធពីរឬបីប៉ុណ្ណោះ ដើម្បីពិភាក្សារឿងនេះ។

នៅដំណាក់កាលបង្កើតសហព័ន្ធ CRF ក៏ដូចជានៅឆ្នាំដំបូងក្រោយពីបង្កើតសហព័ន្ធនេះឡើង គម្រោង SCCRP មានតែឥទ្ធិពលតិចតួចប៉ុណ្ណោះលើការកំណត់រូបរាងអង្គភាព។ ដោយសារសហព័ន្ធ CRF មានបំណងតំណាងឱ្យវិស័យទាំងមូល គម្រោងនេះអាចគាំទ្រក្នុងការដាក់បញ្ចូលអ្នកផលិត (តាមរយៈអង្គការកសិករ) ក្នុងសហព័ន្ធស្រូវអង្ករកម្ពុជាដោយជោគជ័យតែប៉ុណ្ណោះ។ ការផ្តល់យោបល់ផ្សេងទៀត ដូចជាសំណើសុំកំណត់ប្រព័ន្ធក្រុមបោះឆ្នោតមួយ ដើម្បីឱ្យមានតុល្យភាពលើភាពមិនស្មើគ្នានៃការតំណាងរបស់ផ្នែកខុសៗគ្នានៃសង្វាក់តម្លៃ មិនត្រូវបានពិចារណាទេ។

តាមវិធីសាស្ត្រ ដំណើរការចូលរួម និងអត់ធ្មត់ពាក់ព័ន្ធនឹងកំណែទម្រង់សហព័ន្ធ FCRE (ក្នុងបំណងកសាងភាពជាម្ចាស់ តម្លាភាព និងភាពជាតំណាង) គឺផ្ទុយនឹងវិធីសាស្ត្រដែលមានលក្ខណៈការិយាល័យធិបតេយ្យនៃការបង្កើតសហព័ន្ធ CRF ។

## ២.៣. ដែនកំណត់នៃស្ថានភាពបច្ចុប្បន្ន

ភាគីពាក់ព័ន្ធជាច្រើនក្នុងវិស័យស្រូវអង្ករ បានបង្ហាញពីភាពគ្មានជំនឿ ឬគ្មានទំនុកចិត្តពាក់ព័ន្ធនឹងសហព័ន្ធស្រូវអង្ករកម្ពុជា។ នៅដើមឆ្នាំ ២០១៦ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុននាំចេញល្បីៗបានបង្ហាញអំពីកម្រិតជាក់ស្តែងនៃភាពមិនទុកចិត្ត ដែលជាវិបត្តិមួយសម្រាប់សហព័ន្ធ CRF ។

[4] មានតែការកែប្រែលើលក្ខន្តិកៈមួយចំនួនប៉ុណ្ណោះដែលបានជញ្ជូនទៅឱ្យបោះឆ្នោតអនុម័តពីមហាសន្និបាតរបស់សហព័ន្ធ CRF នៅខែកុម្ភៈ ឆ្នាំ ២០១៥។

មិនមានការវាយតម្លៃខាងក្រៅ/ឯករាជ្យអំពីមុខងារ និងស្ថាប័នសហព័ន្ធ CRF ទេ ហើយយើងមិនធ្វើពុតមកទីនេះ ដើម្បីបង្ហាញការវាយតម្លៃរឹងមាំ និងទូលំទូលាយលើមុខងាររបស់សហព័ន្ធ CRF ឡើយ។ ចំណុចខាងក្រោមគឺចាត់ទុកតែជាការអង្កេត និងចំណាប់អារម្មណ៍នានាដែលត្រូវពិចារណា អំឡុងពេលស្វែងរកការកែលម្អស្ថាប័នតាមដែលអាចធ្វើបានប៉ុណ្ណោះ។

- **ភាពជាតំណាង/ ទម្រង់នៃការឯកភាពលើសារគោលនយោបាយរបស់សហព័ន្ធ** CRF ៖ ខណៈដែលសហព័ន្ធ CRF ត្រូវបានទទួលស្គាល់ជាផ្លូវការថាជាអង្គការមួយ ដែលមានការផ្តល់សិទ្ធិបញ្ចេញសំឡេងតំណាងភាគីពាក់ព័ន្ធសេដ្ឋកិច្ចទាំងអស់ក្នុងវិស័យស្រូវអង្ករកម្ពុជា ដោយហេតុនេះហើយទើបភាពជាតំណាងរបស់ខ្លួននោះអាចនឹងក្លាយជាចម្ងល់ដែលពាក់ព័ន្ធទៅនឹងចំណុចគួរពិចារណាពីរខាងក្រោមនេះ៖

  ១. ពុំមានយន្តការណាមួយ (ឧទាហរណ៍ ដូចជាប្រព័ន្ធក្រុមបោះឆ្នោតជាដើម) ដែលអាចធ្វើឱ្យមានតុល្យភាពលើអសមភាពនៃអ្នកតំណាងតាមប្រភេទភាគីពាក់ព័ន្ធផ្សេងៗឡើយ។ ប្រភេទភាគីពាក់ព័ន្ធ ដែលមានអ្នកតំណាងច្រើនជាងគេនៅក្នុងចំណោមសមាជិក គឺមានឥទ្ធិពលខ្លាំងក្នុងការបោះឆ្នោត។

  ២. ពុំមាននីតិវិធីច្បាស់លាស់សម្រាប់សហព័ន្ធ CRF លើការកំណត់ន័យ និងអនុម័ត "ស្ថានភាពគោលនយោបាយ" របស់ខ្លួននៅក្នុងមជ្ឈដ្ឋានខាងក្នុង មុនពេលធ្វើការប្រាស្រ័យ ទាក់ទងទៅមជ្ឈដ្ឋានខាងក្រៅឡើយ ជាពិសេសគឺរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ ឬលក្ខណៈ សាធារណៈតែម្តង។ ពីមុនមក សារគោលនយោបាយដែលបានព្រមព្រៀងនេះមិនត្រូវបានអនុម័តដោយក្រុមផ្សេងៗក្នុងវិស័យស្រូវអង្ករឡើយ ដែលអាចចាត់ទុកថាជាការបម្រុងទុកមុនដ៏ ចាំបាច់មួយដើម្បីទាមទារឱ្យមានការបញ្ចេញសំឡេងតំណាងឱ្យវិស័យទាំងមូល។ ដោយសារតែមិនមានសមភាពនៃចំនួនសមាជិកក្នុង ប្រភេទនីមួយៗ សូម្បីតែសុពលភាពនៃសារគាំទ្រមតិពីការបោះឆ្នោតទូទៅរបស់សមាជិកក៏អាចនឹងនាំឱ្យមានភាពតំណាងលើសលប់ទៅលើប្រភេទមួយចំនួនដែរ (ម្ចាស់រោងម៉ាស៊ីនកិនស្រូវទំនងជានៅក្នុងសមតុល្យនៃសមាជិកតាមប្រភេទ) រហូតដល់ធ្វើឱ្យប៉ះពាល់ដល់ប្រភេទដែលខ្វះខាតភាពតំណាង (ជាពិសេសគឺកសិករ)។ មានតែប្រព័ន្ធក្រុម និងការបោះឆ្នោតអនាមិករបស់ក្រុមតែប៉ុណ្ណោះ (ក្រុមមួយឆ្លើយតបទៅនឹងប្រភេទអ្នកដើរតួក្នុងខ្សែសង្វាក់តម្លៃ) ដែលអាចធ្វើឱ្យមានតុល្យភាពលើការតំណាងដែលអសមភាពនេះបាន។

- **ទម្រង់នៃការបោះឆ្នោតក្រុមប្រឹក្សាភិបាល មិនធានាបាននូវការគាំទ្រ និងការទទួលស្គាល់យ៉ាងរឹងមាំនៃសមាជិកក្រុមប្រឹក្សាភិបាលពីសំណាក់សមាជិកសហព័ន្ធ** CRF **ទាំងអស់ទេ។** សមាជិកដទៃទៀត (រួមមាន ១១ រូប) នៃក្រុមប្រឹក្សាភិបាល ត្រូវបានបោះឆ្នោតជ្រើសរើសក្នុងដំណើរការមួយដែលអ្នកបោះឆ្នោតអាចជ្រើសយកឈ្មោះបេក្ខជនបានតែមួយគត់ពីក្នុងបញ្ជី ជំនួសដោយការផ្តល់សិទ្ធិគូសយកឈ្មោះទាំងដប់មួយ ដើម្បីបំពេញតំណែងទាំងដប់មួយនោះ លើកលែងតែប្រធានក្រុមដែលត្រូវបានបោះឆ្នោតជ្រើសរើសដាច់ដោយឡែក និងតំណាងកសិករដែលត្រូវបានបោះឆ្នោតក្នុងចំណោមសហព័ន្ធ FO ។ ហេតុនេះហើយទើបសមាជិកក្រុមប្រឹក្សាភិបាលត្រូវជាប់ឆ្នោតដោយសំឡេងតិចតួច

ប៉ុណ្ណោះ។ ឧទាហរណ៍ ការបោះឆ្នោតក្រុមប្រឹក្សាភិបាលសហព័ន្ធ CRF លើកចុងក្រោយ (ឆ្នាំ ២០១៦) អ្នកចុងក្រោយបង្អស់ដែលបានជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាភិបាលបានទទួលការបោះឆ្នោតត្រឹមតែ ៨ សំឡេងតែប៉ុណ្ណោះ (ក្នុងចំណោមអ្នកបោះឆ្នោតសរុប ១៩៣ នាក់)។ ប្រព័ន្ធនេះមិនធានាបាននូវមូលដ្ឋានរឹងមាំសម្រាប់សមាជិកក្រុមប្រឹក្សាភិបាលឡើយ។

- ***តួនាទី ភារកិច្ច និងទម្រង់នៃសមាសភាពនៃគណៈកម្មាធិការជំនួយហាក់ដូចជាមិនមានលក្ខណៈផ្លូវការច្បាស់លាស់នៅឡើយ។*** សហព័ន្ធ CRF បង្កើតគណៈកម្មាធិការជំនួយមួយចំនួន ដើម្បីដោះស្រាយ និងសម្រេចចិត្តលើផ្នែកផ្សេងៗនៃសកម្មភាពរបស់សហព័ន្ធ CRF ។ ជាឧទាហរណ៍៖ គណៈកម្មាធិការជំនួយផ្នែកលើកកម្ពស់ទីផ្សារសាកល គណៈកម្មាធិការជំនួយផ្នែកគ្រាប់ពូជ និងកសិកម្ម។ល។ ដំបូងឡើយ គណៈកម្មាធិការទាំងនេះហាក់ដូចជាត្រូវបានបង្កើតឡើងក្នុងមូលដ្ឋានស្ម័គ្រចិត្តទេ ប៉ុន្តែបន្ទាប់ពីការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាភិបាលសហព័ន្ធ CRF អាណត្តិទីពីររួច សមាសភាពគណៈកម្មាធិការជំនួយផ្សេងៗត្រូវប្តូរផ្លាស់ ហើយគណៈកម្មាធិការថ្មីត្រូវបានតែងតាំងឡើងដោយ គណៈគ្រប់គ្រងសហព័ន្ធ CRF តែឯកឯងប៉ុណ្ណោះ ដែលនាំឱ្យមានការមិនទុកចិត្តពីសមាជិកមួយចំនួន (ជាពិសេសអ្នកដែលត្រូវបានបណ្តេញចេញពីគណៈកម្មាធិការជំនួយមុនៗ!)។

# ៣. ការណែនាំវិធីសាស្ត្រផ្សេងៗសម្រាប់ការបង្កើតអង្គការអន្តរវិជ្ជាជីវៈ

តាមបទពិសោធន៍អន្តរជាតិ និងស្ថានភាពក្នុងវិស័យស្រូវអង្ករកម្ពុជានាពេលបច្ចុប្បន្ននេះ ផ្នែកចុងក្រោយនេះបានកំណត់ជូននូវការណែនាំវិធីសាស្ត្រមួយចំនួនដែលអាចនឹងមានប្រយោជន៍ ប្រសិនបើអាជ្ញាធរសាធារណៈកម្ពុជាមានបំណងគាំទ្រដល់ការអភិវឌ្ឍបន្ថែមទៀតនៃអង្គការអន្តរវិជ្ជាជីវៈក្នុងវិស័យស្រូវអង្ករ ឬសម្រាប់ខ្សែសង្វាក់តម្លៃផ្សេងៗ។

## ៣.១. ប្រព័ន្ធក្រុមបោះឆ្នោតដើម្បីធានា (ក្នុងលក្ខន្តិកៈ) បាននូវគោលការណ៍មូលដ្ឋានគ្រឹះនៃភាពជាតំណាង

ដើម្បីបង្កើតអង្គការអន្តរវិជ្ជាជីវៈពិតប្រាកដមួយ ជាការសំខាន់ គឺអ្នកតំណាងនៅក្នុងវិស័យស្រូវអង្ករកម្ពុជា (ឬវិស័យដែលដូចគ្នា) ទាំងមូលត្រូវមានតុល្យភាពលើការតំណាងតាមប្រភេទនៃភាគីពាក់ព័ន្ធ។ តាមធម្មតា គឺការរៀបចំនេះគឺធ្វើឡើងដោយប្រព័ន្ធក្រុមបោះឆ្នោត (ជាការសាកល្បង សម្រាប់វិស័យស្រូវអង្ករ៖ អ្នកផលិត ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអ្នកផ្គត់ផ្គង់សម្ភារ+សេវាកម្ម ដែលក្រុមនីមួយៗតំណាងឲ្យ "វិជ្ជាជីវៈ" មួយ និងមានអនុភាពនៃការសម្រេចចិត្តស្មើៗគ្នា។ ការតំណាងនេះមិនកំណត់តែលើចំនួនបុគ្គលក្នុងផ្នែកនីមួយៗ (ឬវិជ្ជាជីវៈ) និងកម្រិតទ្រព្យសម្បត្តិទេ។ ប៉ុន្តែ ប្រព័ន្ធនេះរក្សាប្រជាធិបតេយ្យភាពនៅក្នុងអង្គការ និងបង្ការគម្លាតអំណាច។

នៅក្នុងផ្នែកគ្រប់គ្រងនៃអង្គការនេះ (ក្រុមប្រឹក្សាភិបាល) ចាំបាច់ត្រូវមានការបែងចែកសំឡេងឆ្នោតស្មើៗគ្នាក្នុងចំណោមក្រុមផ្សេងៗគ្នា (ឧទាហរណ៍ ក្រុមនីមួយៗជ្រើសរើសប្រតិភូបីនាក់ចូលក្នុងក្រុមប្រឹក្សាអភិបាល)។

ដើម្បីមានការព្រមព្រៀងគ្នា រាល់ការសម្រេចចិត្តបែបយុទ្ធសាស្ត្រទាំងអស់នឹងត្រូវមានការអនុម័តពីគ្រប់ក្រុមទាំងអស់ (មានន័យថា ចំនួនភាគច្រើននៃអ្នកផលិត + ចំនួនភាគច្រើននៃម្ចាស់រោងម៉ាស៊ីនកិនស្រូវ + ចំនួនភាគច្រើននៃក្រុមហ៊ុននាំចេញ + ចំនួនភាគច្រើននៃអ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្ម)។ ការសម្រេចចិត្តទៅលើយុទ្ធសាស្ត្រ ត្រូវតែធ្វើតាមលក្ខខណ្ឌទាំងពីរដូចខាងក្រោម៖

→ ត្រូវដាក់ស្នើលិខិតស្តីពីស្ថានភាពជូនរដ្ឋាភិបាល ឬដៃគូស្ថាប័ន (ជាផ្នែកមួយនៃតួនាទីសន្ទនាស្តីពីគោលនយោបាយរបស់គណៈកម្មការអន្តរវិជ្ជាជីវៈ)

→ ការកែប្រែលក្ខន្តិកៈឡើងវិញ។

ប្រើប្រាស់ទម្រង់ខុសៗគ្នា ដើម្បីធានាថាអាចកំណត់បាននូវការតំណាងដោយយុត្តិធម៌ និងមានតុល្យភាពក្នុងការពិចារណាលើលក្ខណៈពិសេស និងការរៀបចំខ្សែសង្វាក់តម្លៃ ប៉ុន្តែគោលការណ៍ និងលក្ខណៈវិនិច្ឆ័យនៃភាពជាតំណាងដែលមានតុល្យភាព គឺមិនអាចមើលរំលងបានទេ។

## ៣.២. ហិរញ្ញវត្ថុ និងបរិយាប័ណ្ណ

### ៣.២.១. រក្សាតុល្យភាពរវាងបរិយាប័ណ្ណ និងកម្រិតបដិភាគគ្រប់គ្រាន់

ដូចនេះ មានន័យថា អង្គការវិជ្ជាជីវៈត្រូវការថវិកាជាចាំបាច់ដើម្បីអនុវត្ត និងបន្តសកម្មភាព ធ្វើបដិភាគផ្នែកហិរញ្ញវត្ថុរបស់ខ្លួន (ថ្លៃសមាជិកភាព ថ្លៃសេវា ។ល។) ប៉ុន្តែកម្រិតតម្លៃសមាជិកភាពមិនគួរបង្ករជាឧបសគ្គធំដល់ការចូលរួមពីភាគីពាក់ព័ន្ធផ្នែកសេដ្ឋកិច្ចទេ (ក៏ដូចជាសមាជិកធម្មតាដែរគឺអាចវាយតម្លៃលើការទទួលខុសត្រូវលើគណៈគ្រប់គ្រងរបស់អង្គការ[5])។

តម្លៃសមាជិកធម្មតាត្រូវតែរក្សានៅកម្រិតសមរម្យ ដើម្បីធានាបាននូវការចូលរួម (ជៀសវាងមានវិបត្តិហិរញ្ញវត្ថុក្នុងការចូលរួមជាសមាជិក ឬក្លាយជាសមាជិករបស់ក្រុមប្រឹក្សាអភិបាល)។

ជាផ្នែកមួយនៃដំណើរការកំណែទម្រង់របស់សហព័ន្ធ FCRE ដោយមានការគាំទ្រចូលរួមពីគម្រោង SCCRP នៅចុងឆ្នាំ ២០១៣ ដល់ ខែមករា ឆ្នាំ២០១៤ គឺមានការស្នើប្រព័ន្ធសម្របសម្រួលថ្លៃសមាជិកភាពដ៏គួរឲ្យចាប់អារម្មណ៍មួយ ( ហើយអនុម័តដោយមហាសន្និបាតសហព័ន្ធ FCRE)។ ប្រព័ន្ធនេះមានកម្រិតថ្លៃសមាជិកភាពខុសៗគ្នា (ធម្មតា/ប្រាក់/មាស/ប្លាទីន)។ សំបុត្រចូល (សមាជិកភាពធម្មតា) គួរតែមានតម្លៃសមរម្យសម្រាប់សហព័ន្ធអាចចូលរួមបាន (គ្មានឧបសគ្គហិរញ្ញវត្ថុក្នុងការចូលជាសមាជិក) និងមានជម្រើសបន្ថែមទៀត (សមាជិកភាពពិសេស) ដោយអាចរកបានចំណូលជាច្រើនដើម្បីរ៉ាប់រងលើការចំណាយ។ ប៉ុន្តែ ជាការសំខាន់ខ្លាំងណាស់ដែលត្រូវកត់សម្គាល់ថាការធ្វើ**បដិភាគកម្រិតខ្ពស់ (សមាជិកភាពពិសេស)** គឺអាចផ្តល់ជាអត្ថប្រយោជន៍បន្ថែម (ជាឧទាហរណ៍ មានកន្លែងផ្សាយពាណិជ្ជកម្ម ឬដាក់ឡូហ្គោ/តំណទៅនឹងវិបសាយសមាជិកពីវិបសាយសហព័ន្ធ មានការបញ្ចុះតម្លៃលើសេវាដូចជា ថ្នាក់បណ្តុះបណ្តាល មានឱកាសថ្លែងក្នុង

[5] ចំណុចនេះសំដៅលើប្រការដែលស្នើក្នុងលក្ខន្តិកៈព្រាង CRF ដែលបានពិភាក្សានៅខែកម្ភៈ ឆ្នាំ 2014 ដោយតាមសមាជិកដែលក្រុមប្រឹក្សាភិបាលនឹងទូទាត់បដិភាគកម្រិតខ្ពស់ដ៏សំខាន់...ជាប្រព័ន្ធដែលមានបញ្ហាខ្លាំងណាស់ ដែលតាមអង្គហេតុដែលត្រូវដកសមាជិកដែលមិនមានលទ្ធភាពអង្គុយកៅអីគណៈគ្រប់គ្រងបានចេញ ហើយបង្កើតប្រព័ន្ធធិនិការធិបតេយ្យ។

ព្រឹត្តិការណ៍ដែលរៀបចំដោយសហព័ន្ធ។ល។) ប៉ុន្តែ**មិនអាចផ្តល់អំណាចបន្ថែមក្នុងការគ្រប់គ្រងនៃសហព័ន្ធឡើយ** (ការចូលជាសមាជិកពិសេសមិនអាចជាលក្ខខណ្ឌក្នុងការមានសិទ្ធិចូលជាក្រុមប្រឹក្សាភិបាលឡើយ)។

### ៣.២.២. តម្លាភាពហិរញ្ញវត្ថុ

តើច្បាស់ពេកណាស់មែនទេ ដែលថាការគ្រប់គ្រងមូលនិធិក្នុងគណៈកម្មការអន្តរវិជ្ជាជីវៈត្រូវមានតម្លាភាពយ៉ាងឥតខ្ចោះនោះ? ផែនការសកម្មភាពប្រចាំឆ្នាំ និងផែនការហិរញ្ញវត្ថុពាក់ព័ន្ធត្រូវតែមានការយល់ព្រមពីសមាជិក ហើយត្រូវតែមានតម្លាភាពពេញលេញ និងរាយការណ៍ពីចំណូល និងចំណាយដែលទូទាត់ជាប្រចាំ និងបង្ហាញដល់សមាជិកជាប្រចាំឆ្នាំ។

## ៣.៣. វិធីសាស្ត្រដែលមានការចូលរួម ដើម្បីដោះស្រាយបញ្ហាស្ថាប័ន និងបង្កើតសេវាកម្មជោគជ័យរហ័ស

ភាពជាម្ចាស់គឺសំខាន់ណាស់សម្រាប់ភាពជោគជ័យរបស់អង្គការ ហើយវិធីសាស្ត្រដែលប្រើប្រាស់ដើម្បីគាំទ្រការបង្កើតអង្គការនេះ និងការអមជាមួយនឹងការលេចឡើងនូវអង្គការអន្តរវិជ្ជាជីវៈគឺមានសារៈសំខាន់ណាស់។ ដំណើរការប្រឹក្សាយោបល់/ចូលរួមគឺសំខាន់ណាស់ ក្នុងការបង្កើតអង្គការដែលមានតម្លាភាព ប្រជាធិបតេយ្យ និងមានភាពជាតំណាង។

គោលការណ៍ខាងក្រោមនេះជាលក្ខណៈនៃវិធីសាស្ត្រដែលគម្រោង SCCRP បានប្រើប្រាស់ដើម្បីគាំទ្រកំណែទម្រង់របស់សហព័ន្ធ FCRE ក្នុងឆ្នាំ ២០១៣ ហើយពួកយើងគិតថាគោលការណ៍ទាំងនេះនៅតែជាការណែនាំវិធីសាស្ត្រដែលមានសុពលភាព៖

- ការរួមបញ្ចូលនៃដំណើរការកំណែទម្រង់រចនាសម្ព័ន្ធជាមួយនឹងវិធានការអនុវត្ត/សេវាកម្មជោគជ័យរហ័ស ដើម្បីសម្រេចបានមតិរួមរបស់សមាជិក (រួមជាមួយការគាំទ្រផ្នែកថវិកា)។
- ដំណើរការពិគ្រោះយោបល់យ៉ាងអត់ធ្មត់ និងតាមដំណាក់កាល ផ្អែកលើការប្រឹក្សាយោបល់ទ្វេភាគី និងសិក្ខាសាលាប្រឹក្សាយោបល់ទ្រង់ទ្រាយធំ ពន្យល់ជាមុនសិននូវអត្ថន័យទូទៅនៃស្ថាប័នដែលចង់បាន និងពីគោលការណ៍សំខាន់ដែលគាំទ្រដោយភាគីពាក់ព័ន្ធ មុននឹងបង្កើតច្បាប់តាមដំណាក់កាល (លក្ខន្តិកៈ និងច្បាប់) ដែលតំណាងឱ្យគោលការណ៍ទាំងនោះ។
- ការចូលរួមរបស់ដៃគូជាផ្លូវការ(អនុស្សារណៈនៃយោគយល់គ្នា) រវាងអង្គការអន្តរវិជ្ជាជីវៈ និងស្ថាប័នគាំទ្រ៖ កំណត់ន័យ និងចូលរួមផ្តល់សុពលភាពវិធីសាស្ត្រជាផ្លូវការ អនុវត្តតាមជំហានទាំងអស់របស់ដំណើរការ និងការប្តេជ្ញាចិត្តរបស់ភាគីទាំងសងខាងក៏ដូចជាគោលដៅ និងលក្ខខណ្ឌតាមដំណាក់កាល ដើម្បីសម្រេចបានការគាំទ្រ (ជាពិសេសមូលនិធិ)។ ទម្រង់ច្បាស់លាស់នៃការត្រួតពិនិត្យ និងការសម្របសម្រួលក៏ត្រូវបានកំណត់ន័យដែរ។ (អ្នកអានអាចផ្អែកលើអនុស្សារណៈនៃយោគយល់គ្នាដែលបានចុះហត្ថលេខាក្នុងខែកញ្ញា ឆ្នាំ ២០១៣ រវាងគម្រោង SCCRP និងសហព័ន្ធ FCRE ជាឧទាហរណ៍)។

ចំណុចជាក់លាក់ដែលមានការសរសើរពីសមាជិកសហព័ន្ធ FCRE ក្នុងដំណើរការគាំទ្រអង្គការនេះក្នុងឆ្នាំ ២០១៣ (ដែលអាចលើកឡើងក្នុងករណីស្រដៀងគ្នា)៖ ផ្តល់ភារកិច្ចជ្រើសរើសបុគ្គលិកឱ្យស្ថាប័នធនធានមនុស្ស៖ នេះមានសារប្រយោជន៍ មិនត្រឹមតែដើម្បីរកឱ្យបាន និងជ្រើសរើសបុគ្គលិកមានសម្បត្តិវិជ្ជាជីវៈខ្ពស់ប៉ុណ្ណោះទេ ថែមទាំងដើម្បីបង្ការមន្ទិលសង្ស័យអំពីបក្សពួកនិយម/អនុគ្រោះនិយមក្នុងដំណើរការជ្រើសរើសបុគ្គលិកទៀតផង។

## ៣.៤. ការគាំទ្រការចូលជាសមាជិក និងការចូលរួមរបស់ភាគីពាក់ព័ន្ធដែលទន់ខ្សោយជាង

ប្រភេទជាក់លាក់នៃតួអង្គចូលរួម អាចជាត្រូវការការគាំទ្របន្ថែមដើម្បីអាចដំណើរការបាន និងដើម្បីធានានូវការតំណាងរបស់ពួកគេ។ ស្របជាមួយនឹងដំណើរការបង្កើតអង្គការអន្តរវិជ្ជាជីវៈ ការគាំទ្រអាចជាត្រូវផ្តល់ទៅកាន់ក្រុមដែលទន់ខ្សោយ និងងាយរងគ្រោះជាង (ដែលមានធនធានតិច ចំណេះដឹងតិច លទ្ធភាពទទួលព័ត៌មាន និងទាក់ទងជាមួយអ្នកសម្រេចចិត្តមានកំណត់...)។

ជាធម្មតា ក្នុងករណីដែលគណៈកម្មការអន្តរវិជ្ជាជីវៈស្ថិតនៅក្នុងវិស័យកសិកម្ម នោះកសិករធន់តូចប្រហែលត្រូវការការគាំទ្រច្រើនជាងនេះដើម្បីអាចចូលរួមក្នុងដំណើរការនេះបាន។

## ៣.៥. តើមានបទបញ្ញត្តិស្តីពីអង្គការវិជ្ជាជីវៈទេ?

ប្រសិនបើរដ្ឋាភិបាលកម្ពុជាមានបំណងបង្កើនការបង្កើតអង្គការវិជ្ជាជីវៈ ដើម្បីពង្រឹងការអភិវឌ្ឍ និងការប្រកួតប្រជែងលើវិស័យកសិកម្មចំណីអាហាររបស់ខ្លួន ហើយជាពិសេសប្រសិនបើរដ្ឋាភិបាលពិចារណាផ្តល់សិទ្ធិពិសេសទៅអង្គការនេះ (ដូចជាទទួលសិទ្ធិផ្តាច់មុខដើម្បីតំណាង ភ្នាក់ងារពាក់ព័ន្ធសេដ្ឋកិច្ចក្នុងខ្សែសង្វាក់តម្លៃពិតប្រាកដ និងកំណត់ច្បាប់ដែលនឹងដាក់ឱ្យប្រើប្រាស់បន្ថែមទៅភ្នាក់ងារពាក់ព័ន្ធក្នុងវិស័យដែលផ្តល់ឱ្យ) នោះគឺជាការស្របតាមការពេញចិត្តក្នុងការកំណត់លក្ខណ្ឌបទបញ្ញត្តិគោល សម្រាប់ធ្វើឱ្យអង្គការទាំងនេះមានការទទួលស្គាល់ថាជាអ្នកតំណាងគណៈកម្មការវិជ្ជាជីវៈ។